**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
៣*៧

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
លេខ ២៥៨ ស.អ.យ.

រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៦

# ប្រកាស
## ស្តីពី
## ការទទួលស្គាល់ជនពិការដើម្បីទទួលបានរបបគោលនយោបាយចំពោះជនពិការក្រីក្រ នៅតាមសហគមន៍ នៃខេត្តប៉ៃលិន

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ស្តីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍
- បានឃើញប្រកាសលេខ ១៩៥២ ស.អ.យ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍សម្រាប់ខេត្តប៉ៃលិន
- យោងសំណើលេខ ១៨៩៧/១៥ ប.ល ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់គណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍សម្រាប់ខេត្តប៉ៃលិន

## សម្រេច

**ប្រការ១.-**

ត្រូវបានទទួលស្គាល់ជនពិការចំនួន ២៣២ (ពីររយសាមសិបពីរ) នាក់ (ដូចមានរាយនាមក្នុងតារាងឧបសម្ព័ន្ធជូនភ្ជាប់មកជាមួយ) ជាជនពិការក្រីក្រនៃខេត្តប៉ៃលិន ដើម្បីទទួលបានរបបគោលនយោបាយដូចមានចែង

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ, ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726086

ក្នុងអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ស្តីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ ចាប់ពីខែមករា ឆ្នាំ២០១៦ នេះតទៅ។

**ប្រការ២.-**

ជនពិការក្រីក្រខាងលើ ត្រូវទទួលបានរបបគោលនយោបាយតាមរយៈប័ណ្ណសង្គមកិច្ច ដែលចេញដោយគណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍សម្រាប់ខេត្តប៉ៃលិន ដែលផ្តល់អត្ថប្រយោជន៍ដូចខាងក្រោម៖

- ទទួលបានរបបគោលនយោបាយឧបត្ថម្ភជីវភាពរស់នៅ ២០ ០០០ (ពីរម៉ឺន) រៀល ក្នុង ០១ (មួយ) ខែ ក្នុងរយៈពេលកំណត់ ដែលមានការវាយតម្លៃដោយគណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍សម្រាប់ខេត្តប៉ៃលិន។ របបគោលនយោបាយនេះ នឹងត្រូវបើកផ្តល់តាមប្រព័ន្ធធនាគារ ដែលតម្រូវឱ្យជនពិការដែលមានរាយនាមនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រការ១ បង្កើតគណនីផ្ទាល់ខ្លួន នៅធនាគារអេស៊ីលីដា ភីអិលស៊ី។
- ទទួលបានរបបគោលនយោបាយបន្ថែមពីមូលនិធិជនពិការ រួមមានៈ
    - សេវាស្តារលទ្ធភាពពលកម្មដោយឥតគិតថ្លៃពីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា
    - ប្រាក់ឧបត្ថម្ភសម្រាប់អាហារក្នុងអំឡុងពេលទទួលសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា ក្នុង ០១ (មួយ) ថ្ងៃ ៣ ០០០ (បីពាន់) រៀល
    - ប្រាក់ឧបត្ថម្ភសោហ៊ុយសម្រាប់ការធ្វើដំណើរមកទទួលសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា ទៅមក ១០ ០០០ (មួយម៉ឺន) រៀល
    - ប្រាក់ឧបត្ថម្ភ ៣០ ០០០ (បីម៉ឺន) រៀល ក្នុង ០១ (មួយ) ឆ្នាំ សម្រាប់ការពិនិត្យ ព្យាបាល ថែទាំសុខភាពនៅតាមមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក។

**ប្រការ៣.-**

របបគោលនយោបាយខាងលើ អាចត្រូវបានផ្តល់បន្ត ឬផ្អាកតាមរយៈការត្រួតពិនិត្យ និងវាយតម្លៃពីគណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍សម្រាប់ខេត្តប៉ៃលិន ដោយមានការចេញប្រកាសទទួលស្គាល់ ដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានសុខុមាលភាពជនពិការ ប្រធាននាយកដ្ឋាន

ហិរញ្ញវត្ថុ និងផ្គត់ផ្គង់ នាយកមូលនិធិជនពិការ ប្រធានគណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍សម្រាប់ខេត្តប៉ៃលិន ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តប៉ៃលិន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

វង សូត

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្តប៉ៃលិន

-ក្រុមប្រឹក្សាសកម្មភាពជនពិការ

-ដូចប្រការ១ និងប្រការ៥

-ឯកសារ កាលប្បវត្តិ